UNITED NATIONS

OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES

BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

United Nations
Human Rights
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS

# សេចក្តីថ្លែងការណ៍របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា

ភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានការសោកស្តាយជាថ្មីម្តងទៀតថា តុលាការត្រូវបានគេប្រើប្រាស់ ដើម្បីប្រតិកម្មតបទៅនឹងបញ្ហាដែលជាប្រយោជន៍សាធារណៈ ដែលបញ្ហានោះអាចត្រូវបានដោះស្រាយក្នុងលក្ខណៈចំហរ បែបស្ថាបនាជាងនេះ តាមរយៈការជជែកពិភាក្សាជាសាធារណៈក្នុងស្ថាប័នប្រជាធិបតេយ្យរបស់កម្ពុជា ។ លោក សម រង្ស៊ី ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលពីរឆ្នាំ ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងបទញុះញង់ឲ្យមានការរើសអើងពូជសាសន៍ (មាត្រា៥២ និងមាត្រា៦១ នៃច្បាប់អ៊ុនតាក់ តាមបញ្ញត្តិដាច់ដោយឡែកពីគ្នា) ។ អ្នកស្រី មាស ស្រី និងលោក ព្រំ ជា ត្រូវបានតុលាការដដែលនេះ ផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលមួយឆ្នាំ ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ។ អ្នកទាំងបីនេះ ត្រូវបានតុលាការដាក់ទោសបន្ថែម ដោយពិន័យជាប្រាក់យ៉ាងច្រើន ចាប់ពី ៥ លានទៅ ៥០ លាន រៀល ។

លោក សម រង្ស៊ី ត្រូវបានចោទប្រកាន់ថា រូបគាត់ផ្ទាល់បានដកតម្រុយបង្គោលព្រំដែន នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ ក្នុងភូមិមួយជិតព្រំដែន ក្នុងខេត្តស្វាយរៀង ជាប់នឹងប្រទេសវៀតណាម ។ ក្នុងនាមជាសមាជិករដ្ឋសភាមួយរូប និងជាមេដឹកនាំគណបក្សប្រឆាំង គាត់គួរតែបានលើកយកកង្វល់របស់គាត់អំពីដំណើរការបច្ចុប្បន្ននៃការកំណត់ព្រំដែន និងបានស្វែងរកការពន្យល់បំភ្លឺពីអាជ្ញាធរពាក់ព័ន្ធ ឬពីគណៈកម្មាធិការព្រំដែន ឬបានលើកយកបញ្ហាទាំងនេះទៅពិភាក្សាក្នុងរដ្ឋសភា ឬពុំនោះទេជាសាធារណៈ ។

សវនាការជម្រះក្តីនេះ បានធ្វើឡើងនៅថ្ងៃទី២៧ ខែមករា នៅតុលាការខេត្តស្វាយរៀង ។ នៅអាគារតុលាការមានកំលាំងសន្តិសុខដាក់ពង្រាយយ៉ាងក្រាស ។ សាធារណៈជនដែលបានជ្រើសសម្រាំង រាប់ទាំងអ្នកភូមិ និងអាជ្ញាធរឃុំ និងសមាជិករដ្ឋសភាមួយចំនួនពីគណបក្សសម រង្ស៊ី ត្រូវបានគេអនុញ្ញាតឲ្យចូលក្នុងបន្ទប់សវនាការ ទោះបីជាកន្លែងមាននៅទំនេរក្តី ។ អ្នកសារព័ត៌មានមិនត្រូវបានគេអនុញ្ញាតឲ្យចូលក្នុងបន្ទប់សវនាការនេះទេ ។ អ្នកសង្កេតការណ៍សិទ្ធិមនុស្សពីរនាក់ រាប់ទាំង OHCHR ផង ត្រូវបានគេអនុញ្ញាតឲ្យសង្កេតការណ៍ការជម្រះក្តីនេះ ។ ខណៈដែល OHCHR គ្មានតួនាទីក្នុងការសំរេចលើអង្គសេចក្តីនៃករណីនេះ OHCHR បានសង្កេតឃើញថា មានករណីជាច្រើនដែលប្រធានតុលាការនេះមិនបានឃាត់មេធាវីខាងភាគីរដ្ឋប្បវេណី ដែលបានវាយប្រហារដោយពាក្យសំដីទៅលើជនជាប់ចោទនិងមេធាវីរបស់គាត់ ក្នុងលក្ខណៈឈ្លានពាន ។ នីតិវីធីត្រឹមត្រូវនៃច្បាប់ និងបទដ្ឋានអន្តរជាតិចែងថា សវនាការត្រូវធ្វើជាសាធារណៈ និងត្រូវគោរពគោលការណ៍ស្មើភាពនៃគូក្តី មានន័យថា គ្រប់គូភាគី ត្រូវតែបានប្រព្រឹត្តដោយគោរពតាមគោលការណ៍ស្មើភាព ។

ការកំណត់ព្រំដែន គឺជាបញ្ហាសំខាន់មួយនៃអធិបតេយ្យរដ្ឋ ។ ជានិច្ចកាល វាគឺជាដំណើរការជជែកពិភាក្សាមួយដែលស្មុគ្រស្មាញ និងមានចរិតនយោបាយ ដែលទាក់ទងនឹងប្រទេសជិតខាង ការចរចាវេទយិត និងដែលងាយនឹងបញ្ឆេះមនោសញ្ចេតនារបស់ប្រជាជន ។ តាមប្រវត្តិកន្លងមក បញ្ហានេះបាននាំឲ្យមានជំលោះយ៉ាងធ្ងន់ធ្ងររវាងប្រទេសកម្ពុជា និងប្រទេសជិតខាងខ្លួន ។ ប្រការដែលសំខាន់នោះ បញ្ហានេះត្រូវតែបានគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្ន មិនត្រឹមតែដោយរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយគណបក្សនយោបាយនានាផងដែរ ដោយភាពអត់ធ្មត់ តាមរយៈការទូត ដោយសមហេតុផល និងមានការទទួលខុសត្រូវ ។

នៅក្នុងសង្គមប្រជាធិបតេយ្យ អ្វីដែលគេចង់បានគឺគោលនយោបាយ ឬសេចក្តីសំរេចនានារបស់រដ្ឋាភិបាល ត្រូវបានដោះស្រាយតាមរយៈការជជែកពិភាក្សាគ្នាជាសាធារណៈ ។ បើពិនិត្យទៅលើទស្សនទានខាងសិទ្ធិមនុស្សវិញ ប្រតិកម្មដែលប្រសើរបំផុតទៅនឹងការចោទប្រកាន់ណាមួយនោះ គឺត្រូវប្រតិកម្មផ្អែកលើការពិត អង្គហេតុ និងភស្តុតាង ហើយប្រសិនជាអាចធ្វើបាន ត្រូវធានាឲ្យកិច្ចដំណើរ និងការជជែកពិភាក្សាមួយមានតម្លាភាព ។ ដើម្បីអាចធ្វើដូចនេះបាន មេដឹកនាំនយោបាយ គួរជៀសវាងការប្រើប្រាស់បញ្ហាព្រំដែន ដើម្បីយកចំណេញខាងនយោបាយ តាមរយៈការបំផុសចិត្តប្រជាជនឲ្យប្រឆាំងប្រជាជន និងប្រទេសជិតខាង ។ នេះជាផ្លូវមួយដែលរអិលខ្លាំង ដែលអាចនាំទៅរកជំលោះ និងអំពើហឹង្សាថែមទៀត៕